E61

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គភាពគាំពារជនរងគ្រោះ
Victims Support Section
Section d'appui aux victimes

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / 03 / 2011
ម៉ោង (Time/Heure): 11:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អនុស្សរណៈ អន្តរការិយាល័យ

**គោរពជូន:** លោកចៅក្រម **និល ណុន**
ប្រធានអង្គជំនុំជម្រះសាលាដំបូង និង
លោក លោកស្រី ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះ
សាលាដំបូងនៃ អ.វ.ត.ក

កាលបរិច្ឆេទ : ០២ មីនា ២០១១

**សាធារណៈ / Public**

យោង : VSS-២០១១-00២ (TC)

**គោរពជូនពី:** រោង ឈុង
ប្រធានអង្គភាពគាំពារជនរងគ្រោះ

**កម្មវត្ថុ:** សំណើសុំផ្លាស់ប្តូរអ្នកតំណាងផ្នែកច្បាប់នៃអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអាសយដ្ឋាន នៅសហរដ្ឋអាមេរិក ចំនួន៤៣នាក់ ក្នុងសំណុំរឿង00២

១. អង្គភាពគាំពារជនរងគ្រោះសូមបញ្ជូនសំណើរបស់មេធាវី Lyma Nguyen ស្នើសុំផ្ទេរកូនក្តីចំនួន៤៣នាក់ ដែលមានអាសយដ្ឋាននៅសហរដ្ឋអាមេរិកជូនមេធាវី Nushin Sarkarati។ មេធាវី Nushin Sarkarati មានសិទ្ធិអាចតំណាងកូនក្តីនៅចំពោះមុខ អ.វ.ត.ក បន្ទាប់ពីបានធ្វើសច្ចាប្រណិធាន និងចុះបញ្ជីនៅអង្គភាពគាំពារជនរងគ្រោះរួចហើយ។ សូមមេត្តាពិនិត្យឯកសារដែលមានភ្ជាប់។

២. សូមជម្រាបជូនថាអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៤១នាក់ បានដាក់ទំរង់បែបបទព័ត៌មានរបស់ខ្លួនតាមរយៈវិទ្យាស្ថានស្រាវជ្រាវកិច្ចការសង្គមកម្ពុជា (ASRIC) ដែលមានការិយាល័យនៅសហរដ្ឋអាមេរិក ហើយអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ២នាក់ផ្សេងទៀត បានដាក់ទំរង់បែបបទព័ត៌មានតាមរយៈអង្គភាពគាំពារជនរងគ្រោះដោយខ្លួនឯងផ្ទាល់។ កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០ តាមរយៈដីកាលេខ D៣៣៧/១០ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានចាត់តាំងមេធាវី Lyma Nguyen និង មេធាវី នី ចាន់ឌី (ត្រូវបានជំនួសដោយមេធាវី សំ សុគង់) ឲ្យតំណាងផ្នែកច្បាប់ជូនពួកគេជាបណ្តោះអាសន្ន។ ក្រោយមក មេធាវី Lyma Nguyen និង មេធាវី សំ សុគង់ និង វិទ្យាស្ថានស្រាវជ្រាវកិច្ចការសង្គមកម្ពុជា (ASRIC) បានស្នើសុំមេធាវី Nushin Sarkarati ដែលមកពីមជ្ឈមណ្ឌលសំរាប់ភាពយុត្តិធម៌

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

និងគណនេយ្យភាព (CJA) ដែលមានការិយាល័យនៅសហរដ្ឋអាមេរិកឱ្យទទួលធ្វើជាអ្នកតំណាងផ្នែកច្បាប់ជាអចិន្ត្រៃយ៍ជូនអ្នកសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីទាំង ៤៣នាក់។

៣. ដើម្បីជាប្រយោជន៍ផ្នែកយុត្តិធម៌ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគួរតែបន្តទទួលបានការតំណាងផ្នែកច្បាប់ដែលមានស្ថានភាពដូចគ្នាទៅនឹងការតែងតាំង និងការរៀបចំ ដោយសហចៅក្រមស៊ើបអង្កេតនៅដំណាក់កាលមុនបញ្ជូនរឿងទៅជំនុំជម្រះ ហើយជាការសមរម្យដែលអនុញ្ញាតឱ្យមេធាវី Nushin Sarkarati មកបន្តធ្វើជាតំណាងផ្នែកច្បាប់រួមគ្នាជាមួយនឹងសហមេធាវីជាតិដែលមានស្រាប់ជូនកូនក្តីទាំងនេះ។ តាមនីតិវិធីមេធាវី Nushin Sarkarati អាចទំនាក់ទំនងកូនក្តីម្នាក់ៗដើម្បីទទួលលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ដើម្បីអនុញ្ញាតឱ្យមេធាវីរូបនេះតំណាងឱ្យពួកគាត់បន្ថែមលើសហមេធាវីដែលមានស្រាប់ ប៉ុន្តែដោយសារតែចំនួនកូនក្តីច្រើន ការលំបាកក្នុងការទំនាក់ទំនង និងពេលវេលាមិនសូវអំណោយផលផងនោះ អង្គភាពគាំពារជនរងគ្រោះសូមស្នើជាយោបល់ថា: យោងតាមមាត្រាទី ២៣ ស្ទួនពីរ ៣.ខ ជាការប្រសើរប្រសិនបើអង្គជំនុំជម្រះសាលាដំបូងអនុវត្តអំណាចរបស់ខ្លួនក្នុងការចេញដីកាតាមមធ្យោបាយនៃការចាត់តាំងឱ្យមេធាវី Nushin Sarkarati តំណាងឱ្យកូនក្តីទាំងនេះ បន្ថែមលើសហមេធាវីជាតិដែលមានស្រាប់។

៤. អង្គភាពគាំពារជនរងគ្រោះ សូមថ្លែងអំណរគុណដល់អង្គជំនុំជម្រះសាលាដំបូងចំពោះការពិចារណា និងអំពីការសម្រេចរបស់ខ្លួនលើបញ្ហានេះ។